សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# អានុភាពដាច់ខាត និង អានុភាពមិនដាច់ខាតនៃ ភាគព្វកិច្ចដោយសាមគ្គីភាព

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **នុត វណ្ណៈ**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ចាំង ស៊ីណាត**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**
ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤

**រក្សាសិទ្ធិដោយ** Khmer Famous

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**..........២

**និយមន័យ:**..........៣

**ក. អានុភាពដាច់ខាតនៃកាតព្វកិច្ចដោយសាមគ្គីភាព**..........៤

ក.១. អានុភាពនៃការទាមទារ និងហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត..........៤

ក.២. អានុភាពដាច់ខាតនៃការសង..........៤

ក.៣. អានុភាពដាច់ខាតនៃការទូទាត់..........៥

ក.៤. អានុភាពដាច់ខាតនៃនវកម្ម..........៥

ក.៥. អានុភាពដាច់ខាតនៃព្យាកុលភាព..........៦

ក.៦. អានុភាពដាច់ខាតនៃការលើកលែង..........៦

ក.៧. អានុភាពដាច់ខាតនៃអាជ្ញាយុកាល..........៧

**ខ. អានុភាពមិនដាច់ខាតនៃកាតព្វកិច្ចដោយសាមគ្គីភាព**..........៨

ខ.១. គោលការណ៍នៃអានុភាពមិនដាច់ខាត..........៨

**សេចក្តីសន្និដ្ឋាន**..........៩

**គន្ថនិទ្ទេស**..........១០

# សេចក្តីផ្តើម

នៅក្នុងសង្គមមួយតែងតែមានបញ្ហាកើតឡើង គ្រាន់តែបញ្ហាទាំងនោះ កើតឡើងតិច ឬកើតឡើងច្រើនតែប៉ុណ្ណោះ។ ជាពិសេសបញ្ហាដែលកើតឡើងជាញឹកញាប់ គឺស្ថិតនៅក្នុងប្រទេសក្រីក្រតែម្តង មានដូចជា ខ្វះលំនៅឋាន ខ្វះអាហារូបត្ថម្ភ គ្មានការងារធ្វើ គ្មានប្រាក់គ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃក្នុងក្រុមគ្រួសារ។ ម្យ៉ាងវិញទៀត ដោយសារជីវភាពក្រីក្រ កូនៗ របស់ពួកគេនឹងបង្ខំចិត្តឈប់រៀនស្វែងរកការងារធ្វើ ដើម្បីជួយសម្រាលស្ថានភាពគ្រួសារបានមួយកម្រិត។ ទាំងនេះហើយ ជាហេតុបង្កឱ្យមនុស្សរស់នៅក្នុងសង្គមនោះ ខ្វះការអប់រំ ខ្វះធនធានមនុស្ស និងអាចបង្កឱ្យមនុស្សរស់នៅក្នុងសង្គមក្លាយទៅជាមនុស្សមិនល្អនៅក្នុងសង្គម។

ក្រៅពីនេះ មានអ្នកបានជំពាក់បំណុលធនាគារ និងអ្នកខ្លះទៀតបានខ្ចីប្រាក់ពីអ្នកចងការប្រាក់រហូតដល់គ្មានប្រាក់សង និងត្រូវធនាគារ និងអ្នកចងការប្រាក់រឹបអូសយកផ្ទះសម្បែង និងដីស្រែចំការរបស់ពួកគាត់ ដែលប្រែក្លាយជាបន្ទុកដ៏ធ្ងន់ថែមទៀតនៅក្នុងគ្រួសារ។

បញ្ហាទាំងនេះ គឺកំពុងតែកើតមាន និងបន្តកើតមានយ៉ាងច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ។ យើងមានករណីជាច្រើនដែលកូនបំណុលបានខ្ចីប្រាក់ធនាគារ និងអ្នកចងការប្រាក់ហើយគ្មានប្រាក់សង និងត្រូវបានរឹបអូសផ្ទះ ដី និងដីស្រែ ចំការ ជាច្រើនរបស់ប្រជាពលរដ្ឋខ្មែរ។

# និយមន័យ:

- **កាតព្វកិច្ចដោយសាមគ្គីភាព:** កាតព្វកិច្ចរបស់កូនបំណុលច្រើននាក់ ដែលក្នុងនោះកូនបំណុលម្នាក់ៗ ឬច្រើននាក់ត្រូវអនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគដោយព្រមគ្នា ឬដោយបន្តបន្ទាប់តាមការទាមទាររបស់ម្ចាស់បំណុល។[1]

- **កូនបំណុល:** អ្នកជំពាក់បំណុល។[2]

- **ម្ចាស់បំណុល:** អ្នកឱ្យគេបុល។[3]

- **នវកម្ម:** សំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និងកូនបំណុលដែលរលត់កាតព្វកិច្ចដើម និងបង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ។[4]

- **ព្យាកុលភាព:** ១/ ករណីដែលកម្មសិទ្ធិ ឬសិទ្ធិប្រត្យក្សផ្សេងទៀត ដែលមានលើវត្ថុតែមួយធ្លាក់ទៅលើបុគ្គលតែម្នាក់ ឬករណី ដែលសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតដែលមានវត្ថុជាសិទ្ធិប្រត្យក្សនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់។ ២/ មធ្យោបាយរំលត់កាតព្វកិច្ច ដែលជនម្នាក់ប្រមូលឱ្យមូលមកលើដៃខ្លួនតែម្នាក់នូវគុណភាពជាម្ចាស់បំណុលផង និងកូនបំណុលផង។[5]

- **អាជ្ញាយុកាល:** អំឡុងពេលមួយ ដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬការរលត់សិទ្ធិណាមួយ។[6]

---

[1] សន្ធានុក្រមផ្នែករដ្ឋប្បវេណី,លេខរៀងទី ៦ ទំព័រទី ១

[2] វចនានុក្រមខ្មែរ សម្ដេចជួន ណាត

[3] វចនានុក្រមខ្មែរ សម្ដេចជួន ណាត

[4] មាត្រា ៤៧៦ និយមន័យនៃនវកម្ម, ទំព័រទី ១៧៣, ក្រមរដ្ឋប្បវេណី ២០០៧

[5] សន្ធានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀងទី ១១០, ទំព័រទី ១៥

[6] សន្ធានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀងទី ១៩៦, ទំព័រទី ២៨

# គ. អានុភាពដាច់ខាតនៃកាតព្វកិច្ចដោយសាមគ្គីភាព

## គ.១. អានុភាពនៃការទាមទារ និងហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត

ការទាមទារឱ្យកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ណាម្នាក់អនុវត្ត និងហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត ដែលកើតឡើងចំពោះកូនបំណុលនោះ ត្រូវមានអានុភាពចំពោះកូនបំណុលផ្សេងទៀតផងដែរ។[7] មានន័យថា ប្រសិនបើម្ចាស់បំណុលទាមទារឱ្យកូនបំណុលម្នាក់សង កូនបំណុលផ្សេងៗ ទៀត ត្រូវអនុវត្តកាតព្វកិច្ចនៃការសងនោះទាំងអស់។ ចំណែក ការផ្អាកអាជ្ញាយុកាលក៏ត្រូវអនុវត្តដូចគ្នាផងដែរ។

**ឧទាហរណ៍:** កូនបំណុលដល់ពេលកំណត់ដែលត្រូវសងប្រាក់ទៅម្ចាស់បំណុល តែកូនបំណុលមិនមានប្រាក់សង ដូច្នេះកូនបំណុលបានស្នើសុំទៅម្ចាស់បំណុល ឱ្យពន្យាពេលនៃការសង បើម្ចាស់បំណុលយល់ព្រមហើយ ការពន្យាពេល ឬការផ្អាកអាយុកាលនេះ ត្រូវមានអនុភាពអនុវត្តចំពោះកូនបំណុលផ្សេងៗ ទៀតដូចគ្នា។

## គ.២. អានុភាពដាច់ខាតនៃការសង

ក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានសង ឬសងដោយវត្ថុជំនួស ឬតម្កល់ អានុភាពនៃការរំលត់កាតព្វកិច្ចដែលបានកើតឡើងដោយការណ៍នេះ ត្រូវមានចំពោះកូនបំណុលផ្សេងទៀតផងដែរ។[8] មានន័យថា ប្រសិនបើ កូនបំណុលម្នាក់បានសងប្រាក់ ឬសងដោយវត្ថុណាមួយជំនួស ទៅម្ចាស់បំណុលរួចហើយ កាតព្វកិច្ចនោះនឹងត្រូវរំលត់ ហើយមានអានុភាពចំពោះកូនផ្សេងទៀតដូចគ្នា។

---

[7] មាត្រា ៩២៤, ទំព័រទី ៣៣២, ក្រមរដ្ឋប្បវេណី ២០០៧

[8] មាត្រា ៩២៥, ទំព័រទី ៣៣២, ក្រមរដ្ឋប្បវេណី ២០០៧

**ឧទាហរណ៍:** កូនបំណុលមានកាតព្វកិច្ចដោយសាមគ្គីភាព មានគ្នា ៥នាក់ ក្នុងនោះបើសិនជាមានកូនបំណុលម្នាក់បានចេញប្រាក់សងទៅម្ចាស់បំណុលរួចហើយ កាតព្វកិច្ចនោះនឹងត្រូវរំលត់ ចំពោះកូនបំណុល ៤នាក់ផ្សេងទៀតដែរ។

## ក.៣. អានុភាពដាច់ខាតនៃការទូទាត់

ក្នុងករណីដែលកូនបំណុល មានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មានសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល ហើយកូនបំណុលនោះបានលើកឡើងនូវការទូទាត់ សិទ្ធិលើបំណុលត្រូវរលត់សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់។[9]

នៅក្នុងពេលដែលកូនបំណុល មានសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មិនទាន់លើឡើងនូវការទូទាត់ កូនបំណុលផ្សេងទៀតអាចបដិសេធការសង ចំពោះបន្ទុករបស់ខ្លួនបាន។[10]

មានន័យថា ប្រសិនបើកូនបំណុលណាម្នាក់មានសិទ្ធីលើបំណុល ចំពោះម្ចាស់បំណុលនោះបានទូទាត់បានសងម្ចាស់រួចហើយ សិទ្ធិលើបំណុលទាំងអស់ត្រូវរំលត់ ចំពោះកូនបំណុលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតដូចគ្នា។ ប៉ុន្តែ បើសិនជាកូនបំណុល មានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់មិនបានលើកឡើងនូវការទូទាត់សង កូនបំណុលផ្សេងទៀតត្រូវមានកាតព្វកិច្ចចំពោះការសងរបស់ខ្លួន។

## ក.៤. អានុភាពដាច់ខាតនៃនវកម្ម

ករណីដែលនវកម្មត្រូវបានធ្វើឡើង រវាងកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ និងម្ចាស់បំណុល សិទ្ធិលើបំណុលត្រូវរលត់ សម្រាប់ផលប្រយោជន៍ របស់កូនបំណុលទាំងអស់។ [11] មានន័យប្រសិនបើ ម្ចាស់បំណុល បានកិច្ចសន្យារវាងកូនបំណុលមានកាតព្វកិច្ច

[9] មាត្រា ៩២៦, កថាខណ្ឌទី ១, ទំព័រទី ៣៣២, ក្រមរដ្ឋប្បវេណី ២០០៧

[10] មាត្រា ៩២៦, កថាខណ្ឌទី ២, ទំព័រទី ៣៣២, ក្រមរដ្ឋប្បវេណី ២០០៧

[11] មាត្រា ៩២៧, ទំព័រទី ៣៣២, ក្រមរដ្ឋប្បវេណី ២០០៧

ដោយសាមគ្គីណាម្នាក់ ថាកិច្ចសន្យានេះត្រូវបានរំលត់ ដោយមូលផ្សេងៗ ទៀត ដូច្នេះ សិទ្ធិលើបំណុលនេះ ត្រូវរំលត់ដូចគ្នា ចំពោះកូនបំណុលដទៃទៀត។

**ឧទាហរណ៍:** ម្ចាស់បំណុល (ក) បានធ្វើកិច្ចសន្យារវាងកូនមានកាតព្វកិច្ចដោយសាមគ្គីភាព (ខ) ថាកិច្ចសន្យាបានរំលត់ដោយ មូលហេតុណាមួយ ដូចនេះ សិទ្ធិលើបំណុលនេះ ក៏ត្រូវរំលត់ចំពោះ កូនបំណុល គ, ឃ, ង និង ច ដែរ។

### ក.៥. អានុភាពដាច់ខាតនៃព្យាកុលភាព

នៅពេលដែលព្យាកុលភាពបានកើតឡើងរវាងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាស់ និងម្ចាស់បំណុល កូនបំណុលនោះត្រូវបានចាត់ទុកថា បានសង។[12] ព្យាកុលភាពគឺជាមធ្យោបាយរំលត់កាតព្វកិច្ច ដែលជនម្នាក់ប្រមូលឱ្យមូលមកលើដៃខ្លួនតែម្នាក់ នូវគុណភាពជាម្ចាស់បំណុលផង និងកូនបំណុលផង។[13]

### ក.៦. អានុភាពដាច់ខាតនៃការលើកលែង

ការលើកលែងកាតព្វកិច្ចទាំងអស់ ដែលបានធ្វើឡើង ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ ត្រូវមានអានុភាពចំពោះតែបន្ទុករបស់កូនបំណុលនោះ សម្រាប់ផលប្រយោជន៍របស់កូនបំណុលផ្សេងទៀត។ [14] មានន័យថា ប្រសិនបើកូនបំណុលណាម្នាក់ត្រូវបានលើកលែងកាតព្វកិច្ចដោយម្ចាស់បំណុល សិទ្ធិបំណុលនោះត្រូវរំលត់ គឺមានអានុភាពរំលត់សិទ្ធិលើបំណុលតែកូនបំណុលម្នាក់នោះប៉ុណ្ណោះ។

**ឧទាហរណ៍:** ម្ចាស់បំណុល (ក) មានកូនបំណុល ៤នាក់ (ខ) (គ) (ឃ) និង (ង)។ ម្ចាស់បំណុល (ក) បានលើកលែងកាតព្វកិច្ចទាំងអស់ ទៅឱ្យកូនបំណុល (ង) តែម្នាក់ ដូច្នេះ សិទ្ធិលើបំណុលទាំងអស់

[12] មាត្រា ៩២៨, ទំព័រទី ៣៣៣, ក្រមរដ្ឋប្បវេណី ២០០៧

[13] សន្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀងទី ១១០, ទំព័រទី ១៥

[14] មាត្រា ៩២៩, កថាខណ្ឌទី ១, ទំព័រទី ៣៣៣, ក្រមរដ្ឋប្បវេណី ២០០៧

របស់ (ង) ត្រូវបានរំលត់។ ប៉ុន្តែ សិទ្ធិលើបំណុល របស់កូនបំណុលផ្សេងទៀត នៅតែបន្តមានដដែល។

ករណីដែលការលើកលែងបានធ្វើឡើងចំពោះតែកាតព្វកិច្ចមួយភាគ ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ អានុភាពនៃការលើកលែងចំពោះកូនបំណុលផ្សេងទៀតត្រូវកើតឡើង តាមសមាមាត្រនៃចំនួនប្រាក់ ក្នុងករណីដែលមានការលើកលែងកាតព្វកិច្ចទាំងអស់។[15]

**ឧទាហណ៍:** ម្ចាស់បំណុល (ក) និងមានកូនបំណុល ៤នាក់ (ខ) (គ) (ឃ) និង (ង)។ ម្ចាស់បំណុលបានលើកលែងកាតព្វកិច្ចចំពោះកូនបំណុល (គ) មួយភាគ ដូច្នេះ កូនបំណុល (ខ) (ឃ) និង (ង) ក៏ត្រូវលើកលែងកាតព្វកិច្ច ឬសិទ្ធិលើបំណុល ដូចគ្នានឹង (គ) ដែរ ដោយចែកតាមសមាមាត្រនៃចំនួនប្រាក់នោះ។

### ក.៧. អានុភាពដាច់ខាតនៃអាជ្ញាយុកាល

ករណីដែលកូនបំណុលមានកាតព្វកិច្ចដោយសាមគ្គីណាម្នាក់ បានលើកឡើងនូវអាជ្ញាយុកាលដែលត្រូវបានសម្រេចចំពោះខ្លួន កូនបំណុលផ្សេងទៀតក៏ត្រូវរួចផុតពីកាតព្វកិច្ច ត្រឹមបន្ទុករបស់កូនបំណុលដែលបានលើកឡើងនូវអាជ្ញាយុកាលនោះ។ [16] អាជ្ញាយុកាលគឺជាអំឡុងពេលមួយ ដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬការរលត់សិទ្ធិណាមួយ។[17]

**ឧទាហរណ៍:** កូនបំណុល (ក) (ខ) និង(គ) បានធ្វើកិច្ចសន្យាខ្ចីប្រាក់ម្ចាស់បំណុល (ង) ចំនួន ៥ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ ដល់ពេលកំណត់ត្រូវសង កូនបំណុលមានកាតព្វកិច្ចដោយសាមគ្គីភាពទាំងអស់ គ្មានប្រាក់សង។ ម្ចាស់បំណុលមិនបានដាក់ពាក្យប្តឹងទៅតុលាការ ទុករហូតដល់ផុតអាជ្ញា

[15] មាត្រា ៩២៩, កថាខណ្ឌទី ២, ទំព័រទី ៣៣៣, ក្រមរដ្ឋប្បវេណី ២០០៧

[16] មាត្រា ៩៣០, កថាខណ្ឌទី ១, ទំព័រទី ៣៣៣, ក្រមរដ្ឋប្បវេណី ២០០៧

[17] សន្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀងទី ១៩៦, ទំព័រទី ២៨

យុកាលនៃការប្តឹង (រយៈពេល ៥ឆ្នាំ) ដូច្នេះ កូនបំណុលមានកាតព្វកិច្ចដោយសាមគ្គីភាពទាំងអស់ត្រូវរំលត់សិទ្ធិលើបំណុលនោះ។

ករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ នៅក្នុងពេលដែលអាជ្ញាយុកាលត្រូវបានសម្រេច តែមិនទាន់ត្រូវបានលើកឡើង កូនបំណុលផ្សេងទៀតអាចលើកឡើងនូវអាជ្ញាយុកាលនោះ ចំពោះបន្ទុករបស់កូនបំណុលដែលអាចលើកឡើងនូវអាជ្ញាយុកាលនោះ។ [18] មានន័យថា ប្រសិនបើ កូនបំណុលណាម្នាក់បានដឹងថា អាយុកាលនៃកាតព្វកិច្ចដោយសាមគ្គីភាពនោះត្រូវរំលត់ ហើយ ខ្លួនមិនបានលើកឡើង កូនបំណុលផ្សេងទៀត អាចលើកឡើងនៅអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះបាន។

# ខ. អានុភាពមិនដាច់ខាតនៃកាតព្វកិច្ចដោយសាមគ្គីភាព

## ខ.១. គោលការណ៍នៃអានុភាពមិនដាច់ខាត

ហេតុដែលបានកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មិនត្រូវមានអានុភាព ចំពោះកូនបំណុលផ្សេងទៀតឡើយ លើកលែងតែហេតុដែលបានកំណត់ពីមាត្រា ៩២៤ (អានុភាពដាច់ខាតនៃការទាមទារ និងហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត) ដល់មាត្រា ៩៣០ (អានុភាពដាច់ខាតនៃអាជ្ញាយុកាល) ខាងនេះ។[19] មានន័យថា ហេតុដែលបានឡើងឬរបស់កូនបំណុលមានកាតព្វកច្ចិដោយសាមគ្គីណាម្នាក់ មិនត្រូវមានអានុភាព ឬប៉ះពាល់ដល់សិទ្ធិលើបំណុលរបស់កូនបំណុលផ្សេងទៀតនោះទេ។

[18] មាត្រា ៩៣០, កថាខណ្ឌទី ២, ទំព័រទី ៣៣៣, ក្រមរដ្ឋប្បវេណី ២០០៧

[19] មាត្រា ៩៣១, ទំព័រទី ៣៣៥, ក្រមរដ្ឋប្បវេណី ២០០៧

# សេចក្តីសន្និដ្ឋាន

កាតព្វកិច្ចដោយសាមគ្គីភាព គឺជាកាតព្វកិច្ចរបស់កូនបំណុលច្រើននាក់ ដែលក្នុងនោះកូនបំណុលម្នាក់ៗ ឬច្រើននាក់ត្រូវអនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគដោយព្រមគ្នា ឬដោយបន្តបន្ទាប់តាមការទាមទាររបស់ម្ចាស់បំណុល។ ហើយកាតព្វកិច្ចដោយសាមគ្គីភាពនេះដែរ គឺមានភាពងាយស្រួលដល់កូនបំណុល និងម្ចាស់បំណុល ដែលក្នុងចំណោមកូនបំណុលទាំងអស់ មានកូនបំណុលតែម្នាក់ក៏បាន អាចសងសិទ្ធិលើបំណុលទៅឱ្យម្ចាស់បំណុល ឬអាចនិយាយបានម្យ៉ាងទៀតថា ម្ចាស់បំណុលអាចមានសិទ្ធិទាមទារសិទ្ធិលើបំណុលរបស់ខ្លួនកូនបំណុលណាម្នាក់ក៏បាន។

សរុបសេចក្តីមក កាតព្វកិច្ចដោយសាមគ្គីភាព គឺជាកាតព្វកិច្ចមួយដែលចងភ្ជាប់ទំនាក់ទំនងរវាងកូនបំណុលច្រើននាក់ ជាមួយនឹងម្ចាស់បំណុលតែម្នាក់ និងត្រូវធ្វើឡើងទៅតាមទម្រង់ និងនីតិវិធីដែលមានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន៕

# គន្ថនិទ្ទេស

- ក្រមរដ្ឋប្បវេណី ២០០៧